# អនុសាសន៍រួម
# របស់អង្គការសង្គមស៊ីវិល និងសហគមន៍ជនជាតិដើមភាគតិច
# ចំពោះផលប៉ះពាល់លើដីធ្លី និងធនធានធម្មជាតិ ពីការអនុវត្តគម្រោងសម្បទានដីសេដ្ឋកិច្ច នៅកម្ពុជា

ខេត្តរតនគិរី ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៤

យើងខ្ញុំជាអង្គការសមាជិក **បណ្តាញជនជាតិដើមភាគតិច និងព្រៃឈើ** និងតំណាងសហគមន៍ជនជាតិដើមភាគតិច **ចំនួន៨សហគមន៍** មកពីបណ្តាខេត្តមួយចំនួនដូចជា៖ ខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តក្រចេះ ខេត្តកំពង់ធំ និងខេត្តព្រះវិហារសូមសំដែងការកោតសរសើរចំពោះកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល លើការគាំទ្រអភិបាលកិច្ចល្អក្នុងវិស័យដីធ្លី និងធនធានធម្មជាតិនៅកម្ពុជា។ ជាពិសេសនាពេលថ្មីៗនេះ រាជរដ្ឋាភិបាលបានចេញសេចក្តីប្រកាសអន្តរក្រសួង ស្តីពី **«ការពង្រឹងការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច»** ដែលមានក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទ ជាសេនាធិការដ្ឋានក្នុងការពង្រឹងការអនុវត្តបទប្បញ្ញត្តិ និងបច្ចេកទេសនានា ដែលទាក់ទងនឹងការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច ក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីឱ្យគម្រោងទាំងអស់ធានាបាននូវការអភិវឌ្ឍប្រកបដោយចីរភាព តម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព។ ជាក់ស្តែងគណៈកម្មការអន្តរក្រសួងបានដកហូតដីសម្បទានសេដ្ឋកិច្ចដែលមិនបានអនុវត្តត្រឹមត្រូវតាមច្បាប់ចំនួន ១៩គម្រោង ក្នុងចំណោម ៣០១គម្រោង គិតត្រឹមខែតុលា ឆ្នាំ២០១៤[1] លើផ្ទៃដីសរុបប្រមាណ ២.២៨៩.៤៩០ ហិកតា។

ជាលទ្ធផលរាជរដ្ឋាភិបាលក៏បានចូលរួមសហការយ៉ាងជិតស្និតជាមួយអង្គការសង្គមស៊ីវិលក្នុងការរៀបចំ សិក្ខាសាលាថ្នាក់តំបន់ស្តីពី **«ការផ្សព្វផ្សាយសេចក្តីប្រកាសអន្តរក្រសួង ស្តីពីការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច»** ដែលបានប្រពឹត្តិធ្វើនៅថ្ងៃ ទី១២ ខែវិច្ឆិកា ឆ្នាំ២០១៤ នៅសណ្ឋាគារ រតនស៊ីធី ខេត្តរតនគិរី ដើម្បីធ្វើការពន្យល់ដល់ អាជ្ញាធរថ្នាក់ខេត្ត អាជ្ញាធរមូលដ្ឋាន សហគមន៍រងផលប៉ះពាល់ អង្គការសង្គមស៊ីវិល អោយយល់ដឹងស៊ីជម្រៅពីខ្លឹមសារ និងចូលរួមអនុវត្ត និងតាមដានលើការអនុវត្តរបស់ក្រុមហ៊ុន។

ទន្ទឹមនឹងសមិទ្ធិផលដែលរាជរដ្ឋាភិបាលសម្រេចបាន សហគមន៍យើងខ្ញុំនៅតែមានបញ្ហាប្រឈមមួយចំនួនកើតមានឡើងដូចខាងក្រោម៖

- ក្រុមហ៊ុននៅតែបន្តឈូសឆាយ ខណៈពេលដែលមានដីទំនាស់មិនទាន់បានដោះស្រាយ។ វិវាទបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ដីធ្លីនឹងធនធានធម្មជាតិ ដូចជា៖ ដីព្រៃអារក្ស ដីព្រៃកប់ខ្មោច ដីស្រែចំការដាំដំណាំជាក់ស្តែង ព្រៃបំរុងទុកដូរវេនដំណាំ ការលុបអូរ ឈូសឆាយព្រៃសង្វាងមាត់អូរ បឹង ត្រពាំង ខឿនប្រសាទបុរាណ បាត់បង់ដើមច្បោះ បាត់បង់ប្រភពប្រើប្រាស់ទឹក ដែនជំរកសត្វព្រៃ។ល។ ករណីនេះកើតឡើងនៅភូមិប្រមេរ ឃុំប្រមេរ ខេត្តព្រះវិហារ ឃុំប៊ូស្រា ឃុំស្រែព្រះ ឃុំស្រែខ្ទុម ខេត្តមណ្ឌលគិរី ឃុំញ៉ាង ឃុំម៉ាលិក ឃុំតាឡាវ ខេត្តរតនគិរី។

[1] គេហទំព័រ ទិន្នន័យពីការអភិវឌ្ឍ (http://www.opendevelopmentcambodia.net/company-profiles/economic-land-concessions/)

- ក្រុមហ៊ុនមិនបានពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋនៅមូលដ្ឋានអំពីផលប៉ះពាល់បរិស្ថាន និងសង្គមជាមុន និងមិនបានអនុវត្តតាមរូបមន្តស្បែកខ្លា។ ករណីនេះកើតឡើងនៅឃុំប្រមេរ ខេត្តព្រះវិហារ ឃុំប៊ូស្រា ឃុំស្រែខ្ទុម ខេត្តមណ្ឌលគិរី ឃុំញ៉ាង ឃុំម៉ាលិក ឃុំតាឡាវ ខេត្តរតនគិរី។
- ជនជាតិដើមភាគតិចរងការគាបសង្កត់សិទ្ធិប្រពៃណី និងគម្រាមកំហែងពីក្រុមហ៊ុន និងអាជ្ញាធរ អោយទទួលយកកម្មសិទ្ធិដីឯកជន។ ករណីនេះកើតឡើងនៅ ឃុំប្រមេ ខេត្តព្រះវិហារ ។
- ការវាស់ដីកម្មសិទ្ធឯកជនជាន់គ្នាតាមរយៈការអនុវត្តបទបញ្ជា ០១ នៅក្នុងឃុំប្រមេរ ខេត្តព្រះវិហារ ធ្វើអោយប៉ះពាល់ដីសមាជិកសហគមន៍ ដែលបំរុងនឹងចុះបញ្ជីដីជាសមូហភាព ដែលបង្ករអោយមានការប្តឹងផ្តល់គ្នាឡើងតុលាការ។
- ការដឹកឈើចូលពីតំបន់ខាងក្រៅដីសម្បទានរបស់ក្រុមហ៊ុន ចេះតែបន្តកើតមានឡើង។ ករណីនេះនៅភូមិពូគង់ ឃុំស្រែព្រះ ខេត្តមណ្ឌលគិរី។

ហេតុដូចនេះ ក្នុងនាមជាអង្គការសង្គមស៊ីវិល និងសហគមន៍ យើងខ្ញុំសូមសំណូមពរយ៉ាងទទូចទៅដល់រាជរដ្ឋាភិបាលកម្ពុជាដូចខាងក្រោម៖

១) គណៈកម្មការអន្តរក្រសួងបន្តផ្សព្វផ្សាយអោយបានទូលំទូលាយ នូវប្រកាសអន្តរក្រសួង និងពង្រឹងការសហការជាមួយសហគមន៍មូលដ្ឋាន និងអង្គការសង្គមស៊ីវិលដើម្បីផ្តល់ព័ត៌មាន និងចូលរួមពិនិត្យតាមដាន វាយតម្លៃការអនុវត្តរបស់ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច។

២) ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទ បង្ហាញនូវឯកសារដែលរួមមាន៖ ផែនទីប្លង់មេ កិច្ចសន្យារបស់ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចជាមុន ដល់អាជ្ញាធរមូលដ្ឋាន សហគមន៍មូលដ្ឋាន និងអង្គការសង្គមស៊ីវិល ដើម្បីជាមូលដ្ឋានក្នុងការផ្ទៀងផ្ទាត់ពិនិត្យ និងវាយតម្លៃ។

៣) គណៈកម្មការអន្តរក្រសួងឈរលើគោលការណ៍អព្យាក្រឹត្យ លើកកម្ពស់សិទ្ធិជនជាតិដើមភាគតិចក្នុងការធ្វើការវិនិច្ឆ័យប្រកបដោយតម្លាភាព លើផលប៉ះពាល់ដីប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិច ដូចជាដីព្រៃកប់ខ្មោច ដីព្រៃអារក្ស ដីព្រៃបំរុងទុកដូរវេណដំណាំ ជាមួយក្រុមហ៊ុនសម្បទានសេដ្ឋកិច្ច ដើម្បីដកដីពីក្រុមហ៊ុនជូនប្រជាពលរដ្ឋតាមរយៈការអនុវត្តយន្តការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច សហគមន៍ព្រៃឈើនិងសហគមន៍តំបន់ការពារធម្មជាតិ។

៤) គណៈកម្មការអន្តរក្រសួងត្រួតពិនិត្យរាល់ការដឹកឈើ និងកាប់ឈើខុសច្បាប់ពីតំបន់ផ្សេងៗនាំចូលមកទីតាំងក្រុមហ៊ុន។

៥) គណៈកម្មការអន្តរក្រសួងកំណត់សមាសភាពស្ថាប័នថ្នាក់ក្រោមជាតិអោយបានច្បាស់ ដើម្បីឲ្យប្រជាពលរដ្ឋងាយស្រួលទំនាក់ទំនង និងរាយការណ៍អំពីករណីប្រឈមផ្សេងៗ។ជាពិសេសកំណត់ពេលវេលាឆ្លើយតបឲ្យបានច្បាស់លាស់ និងសម្រុះសម្រួលបន្ទាន់ពីបញ្ហា របស់ប្រជាពលរដ្ឋ និងក្រុមហ៊ុន។

ក្រុមអង្គការសង្គមស៊ីវិលគាំទ្រ និងទំនាក់ទំនង៖

១) វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា(NGO Forum) លោក តឹក វណ្ណារ៉ា ០១២ ៧៩៣ ៤៨៩
២) មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC)៖ លោក ឯម សុភ័ក្រ្ត ០១២ ៩៧៨ ៩៣៥
៣) អង្គការអភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាព (DPA)៖ លោក ម៉ម សម្បត្តិ ០១២ ៧៧៩ ៧៣៤
៤) អង្គការអភិវឌ្ឍន៍សំលេងសហគមន៍ (BCV)៖ លោកស្រី ព្រី ផល្លីភួង ០១២ ៣០៧ ០២៧
៥) សមាគមន៍យុវជនជនជាតិដើមភាគតិចកម្ពុជា (CIYA)៖ លោក ភាព សុជា ០៩២ ៦១៧ ៩៩០
៦) អង្គការពន្លកខ្មែរ (PKH) ខេត្តព្រះវិហារ៖ លោក អាង ជាតិឡោម ០១២ ៥១៧ ៩៤៣
៧) អង្គការអនុផលព្រៃឈើ (NTFP)៖ លោក ឡុង សេរី ០១២ ៥៥៩ ៤០២
៨) អង្គការសង្គ្រោះជនងាយរងគ្រោះកម្ពុជា (SVC)៖ លោក វ៉ាន់ សាវ៉ាវុធ ០១២ ៥២២ ៨៨១
៩) អង្គការសមាគមខ្មែរលើ (HA) លោកស្រី ដាំ ចាន់ធី ០១២ ៤៣៤ ៦៧០
១០) អង្គការភូមិខ្ញុំ (MVI) លោក ប៉ោ ណារិទ្ធ ០១២ ៣៧១ ០០៣
១១) អង្គការលើកស្ទួយវប្បធម៌ជនជាតិកួយ (OPKC) លោក វង វឿន ០១២ ២៦៧ ៨៨៩
១២) អង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច (ICSO) លោក សៅ វណ្ណសី ០១២ ៨១៣ ៧៤៥
១៣) អង្គការសមាគមអភិវឌ្ឍន៍ជនបទ (RDA) លោក លី ខុម ០១២ ៧៣៤ ៥៦៧
១៤) បណ្តាញសមាជិកសកម្មសិទ្ធិជនជាតិដើមភាគតិច (IRAM) លោក លី លីម ០៨៨ ៦០៦១ ១៥១

តំណាងសហគមន៍គាំទ្រ និងទំនាក់ទំនង៖

១) សហគមន៍ប្រមេរ ខេត្តព្រះវិហារ: លោក ស៊ុត សាវន ០៩៧ ៨៨៩ ៧៣០ ២
២) សហគមន៍ប៊ូស្រា ខេត្តមណ្ឌលគិរី: លោក ប្លាង ស៊ីន ០៩៧ ២១១ ៤២០ ១
៣) សហគមន៍ស្រែអំពិល ខេត្តមណ្ឌលគិរី: លោក ពឹង គ្រេន ០៧១ ៨១៣ ២៤៤ ៧
៤) សហគមន៍ពូគង់ ខេត្តមណ្ឌលគិរី: លោក ដេន ណារ៉ា ០៩៧ ៤៦៦ ៦៥៥ ១
៥) សហគមន៍ស្រែឈូក ខេត្តក្រចេះ លោក អំប្រច់ អន្គន់ ០៩៧ ៦៥៦ ៨១៤ ៤
៦) សហគមន៍ប៉ាគ្លែ ខេត្តក្រចេះ៖ លោក សាំង សាខេន
៧) សហគមន៍ក្បាលអូរធ្មង់ ខេត្តកំពង់ធំ: លោក អ៊ឹង គុង ០៧៧ ៩០៣ ៣៨៥
៨) សហគមន៍ព្រៃឡង់ ខេត្តកំពង់ធំ: លោក សុខ ប្លោក ០៧៧ ៩២២ ៧៥១
៩) សហគមន៍ដីក្រហម ខេត្តក្រចេះ លោក ខាក វង ០៩៧ ៦៥៦ ៣៩៨ ៧
១០) សហគមន៍ច្រាប ខេត្តក្រចេះ៖ លោក ម៉ី ហ៊ាន ០៨៨ ៤៦០ ៧៦៥ ៣
១១) សហគមន៍បឹងពៃ ខេត្តកំពង់ធំ: លោក កែ ឆន ០៩២ ៦១៨ ៩៥៤
១២) សហគមន៍សំអោង ខេត្តកំពង់ធំ: សេក សឿង ០៨៩ ៦៩២ ៩៩១
១៣) សហគមន៍កាណាត ខេត្តរតនគិរី: លោក សល់ ហ្មើយ ០៩៧ ៨០៣ ៦៦០ ៩